**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៧០៥០ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១០

**គោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋាន លោកប្រធាននាយកដ្ឋាន លោកនាយកវិទ្យាស្ថាន**
**លោកអគ្គាធិការ និងលោកប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** សំណើសុំធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ សម្រាប់ឆ្នាំ ២០១១។

អាស្រ័យដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកប្រធាន លោកនាយក និងលោកអគ្គាធិការ មេត្តារៀបចំធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ សម្រាប់ឆ្នាំ ២០១១។ ការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពនេះ មានសារៈសំខាន់ផងដែរសម្រាប់គាំទ្រដល់ផែនការថវិកា និងលទ្ធកម្ម ដើម្បីធានាឲ្យដំណើរការអនុវត្តកម្មវិធីកែទម្រង់ប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកប្រធាន លោកនាយក និងលោកអគ្គាធិការ មេត្តាចាត់ចែងរៀបចំធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពនេះ និងបញ្ជូនមកលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ***<u>អោយបានមុនថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០</u>***។

សូម ឯកឧត្តម លោកប្រធាន លោកនាយក និងលោកអគ្គាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**
**ប្រធានគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត. អ៊ុន - ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន:</u>
- ឯកឧត្តមរដ្ឋលេខាធិការ/ ឯកឧត្តមអនុរដ្ឋលេខាធិការ
- ឯកឧត្តមអគ្គលេខាធិការ/ ឯកឧត្តមអគ្គលេខាធិការរង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជ្រាបជាព័ត៌មាន"